អាជ្ញាធរអប្សរា
APSARA

# បរិស្ថានអង្គរ

បរិស្ថានអង្គរ
ANGKOR EMS

ឆ្នាំទី១ លេខដំបូង　　អង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថាន អាជ្ញាធរអប្សរា　　ថ្ងៃពុធ ទី១៥ ខែតុលា ឆ្នាំ២០០៣




ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពី
*"គំរោង កម្ពុជា_ជប៉ុន ដើម្បីគ្រប់គ្រងបរិស្ថានអង្គរ"*
នៅទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី២៣ខែឧសភាឆ្នាំ២០០៣ ។



## សេចក្តីប្រកាស

ឯកឧត្តម **ប៊ុន ណារិទ្ធ**
ប្រធានអគ្គនាយកអាជ្ញាធរអប្សរា

បេសកកម្មរបស់អាជ្ញាធរអប្សរាគឺ ការការពាររមណីយដ្ឋាន រៀបចំ និងអភិវឌ្ឍន៍តំបន់អង្គរ ដែលជាបេតិកភណ្ឌពិភពលោក សំរាប់ថែរក្សាសម្បត្តិវប្បធម៌ជាតិ និងបំរើឲ្យវិស័យទេសចរណ៍ ។ បច្ចុប្បន្ននេះ តំបន់សៀមរាប_អង្គរ មានការរីកចំរើនគួរឲ្យកត់សំគាល់ សណ្ឋាគារ ផ្ទះសំណាក់ ផ្លូវថ្នល់ ភូមិអ្នកស្រុក សេវាដឹកជញ្ជូនគ្រប់ប្រភេទ ភ្ញៀវទេសចរជាតិ_អន្តរជាតិ ប្រជាជនក្នុងក្រុង អ្នកស្រុករស់នៅក្នុងឧទ្យានអង្គរ បានកើនឡើងយ៉ាងឆាប់រហ័សព្រមៗគ្នា ។

បច្ច័យខាងលើនេះ បាននិងកំពុងប៉ះពាល់ច្រើនដល់បរិស្ថានក្នុងតំបន់ពិសេសនៅអង្គរ ។ អាជ្ញាធរអប្សរា បានសហការជាមួយភាគីចំរុះជប៉ុន ដែលរួមមាន Sophia University, JQA, ISRI និង JQAI ដើម្បីរៀបចំប្រព័ន្ធគ្រប់គ្រងបរិស្ថានមួយ ស្របតាមស្តង់ដារអន្តរជាតិ ក្នុងគោលបំណងថែរក្សាបរិស្ថាន ឲ្យបានល្អជានិរន្ត ។

ក្រោយពីបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៣មក អ្នកជំនាញការបរិស្ថានជប៉ុន ជាបឋម បានធ្វើការបណ្តុះបណ្តាលដល់មន្ត្រីនិយោជិត អាជ្ញាធរអប្សរាទាំងមូល ដើម្បីជាមូលដ្ឋានឈានទៅរកការផ្សព្វផ្សាយ និងការចូលរួមសហការពីស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងព្រះសង្ឃ និងប្រជាពលរដ្ឋ ដែលរស់នៅក្នុងឧទ្យាន ដើម្បីរួមដៃគ្នាអនុវត្តនូវប្រព័ន្ធគ្រប់គ្រងបរិស្ថាននេះ ឲ្យមានប្រសិទ្ធិភាព ។

អាជ្ញាធរអប្សរា បានប្តេជ្ញារួចមកហើយថានឹងរៀបចំបង្កើតប្រព័ន្ធនេះ ឲ្យបានក្នុងរយៈពេលបីឆ្នាំ ។ នៅពេលទទួលបានវិញ្ញាបនប័ត្រហើយ អង្គរនឹងទៅជាបេតិកភណ្ឌពិភពលោកមុនគេបង្អស់ ដែលអនុវត្តប្រព័ន្ធគ្រប់គ្រងបរិស្ថាន ស្របតាមស្តង់ដារអន្តរជាតិ ISO 14001 ។

ដើម្បីឲ្យគោលបំណងរួមនេះសំរេចបាន លុះត្រាតែមន្ត្រីនិយោជិតអាជ្ញាធរអប្សរាទាំងអស់គ្នា ចូលរួមរៀនសូត្រ និងឈានមុខគេ ក្នុងការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងបរិស្ថាននេះ តាមតួនាទី និងភារកិច្ចរបស់ខ្លួន។ ក្រៅពីការការពារបរិស្ថាន ប្រព័ន្ធនេះនឹងនាំមកនូវការសន្សំសំចៃចំណាយផ្នែកហិរញ្ញវត្ថុ និងពេលវេលាក្នុងការគ្រប់គ្រងការងាររបស់អាជ្ញាធរអប្សរា ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ឡើង ។

ជាអវសាន ខ្ញុំសង្ឃឹមជឿជាក់ថា មន្ត្រី និយោជិតអាជ្ញាធរអប្សរាទាំងអស់នឹងចូលរួមរៀនសូត្រជំរុញការងារខាងលើនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ជាពុំខាន ៕

ᨅ✧ᨅ



## សេចក្តីអំពាវនាវ

ឯកឧត្តម **តាន់ សំប៊ុន**
អ្នកតំណាងទទួលបន្ទុកប្រព័ន្ធគ្រប់គ្រងបរិស្ថាន

ជាជំហានដំបូងនៃការគ្រប់គ្រងបរិស្ថានអង្គរ អាជ្ញាធរអប្សរា ៖

១. បានរៀបចំរចនាសម្ព័ន្ធមួយ(ដូចមានចែងក្នុងទំព័រ២) ដែលមានការបែងចែក តួនាទី ភារកិច្ច និងការទទួលខុសត្រូវច្បាស់លាស់ ដើម្បីអនុវត្តប្រព័ន្ធគ្រប់គ្រងមួយស្រប តាមស្តង់ដារអន្តរជាតិ ។
២. កំពុងបង្កើតគំរោងគំរូមួយស្តីពីការគ្រប់គ្រងសំរាមនៅក្នុងឧទ្យានអង្គរ។ គំរោងនេះមានគោលបំណងពីរ ៖ ទី១គឺដើម្បីសិក្សាយល់ដឹងជាគំរូ នូវប្រព័ន្ធគ្រប់គ្រងសំរាមនិងការថែរក្សាសោភ័ណភាពឧទ្យានអង្គរ។ ទី២គឺដើម្បីឈានទៅរកការរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងបរិស្ថានធំមួយស្របទៅតាមតួនាទីរបស់អាជ្ញាធរអប្សរា ។
៣. កំពុងជំរុញធ្វើការសិក្សាអំពីប្រព័ន្ធគ្រប់គ្រងបរិស្ថានរៀងរាល់សប្តាហ៍ ជូនដល់ក្រុមជំរុញការងារបរិស្ថាន ដើម្បីឈានទៅសំរេចគោលដៅខាងលើរបស់យើង ។

អាស្រ័យហេតុនេះ ខ្ញុំសូមអំពាវនាវដល់អ្នកដឹកនាំគ្រប់លំដាប់ថ្នាក់ មន្ត្រីនិយោជិតអាជ្ញាធរអប្សរា ចូលរួមរៀនសូត្រនូវខ្លឹមសារនៃប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ ឲ្យបានគ្រប់ៗគ្នាដើម្បីជាបង្អែកសំរាប់ដំណើរការអភិវឌ្ឍន៍តំបន់អង្គរ ឲ្យរីកចំរើនប្រកបដោយនិរន្តភាពលើគ្រប់វិស័យទាំងអស់ រួមមាន សេដ្ឋកិច្ច ទេសចរណ៍ វប្បធម៌ បរិស្ថាន ជាដើម ៕




## សមាសភាពនៅក្នុងរចនាសម្ព័ន្ធ

(១) *អ្នកដឹកនាំថ្នាក់លើ* គឺ ឯ.ឧ.ប៊ុន ណារិទ្ធ ប្រធានអគ្គនាយក

(២) *អ្នកតំណាងគ្រប់គ្រងបរិស្ថាន* គឺ ឯ.ឧ.តាន់ សំប៊ុនអគ្គនាយករង

(៣) *ក្រុមអ្នកធ្វើសវនកម្មផ្ទៃក្នុង* (នឹងចាត់តាំងនៅថ្ងៃក្រោយ)

(៤) *គណៈកម្មការគ្រប់គ្រងបរិស្ថាន* ប្រធាននាយកដ្ឋានទាំង៦ជាសមាជិក

(៥) *លេខាធិការដ្ឋាន* មាន លោក អ៊ុក ស៊ុនហេង លោក អ៊ុន មណីនីតា និងកញ្ញា សេង សូទ្ធីវ៉ា

(៦) *ក្រុមជំរុញការងារបរិស្ថាន* មាន លោក ស៊ឹម ថន (ន.រមណីយដ្ឋាន និងបុរាណវិទ្យា) លោកវ៉ាន់ យឿយ (ន.អភិវឌ្ឍន៍ក្រុង) លោក ប៉ាវណ្ណហន (ន.អភិវឌ្ឍន៍ទេសចរណ៍អង្គរ) អ្នកស្រី ម៉ៅ សុមាភិវឌ្ឍន៍(ន.រដ្ឋបាលកណ្តាល) កញ្ញា អ៊ុំ ស៊ីណែត(ន.វប្បធម៌និងស្រាវជ្រាវ) និងកញ្ញា តាន់រចនា (ន.អភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម)

## តួនាទី និងការទទួលខុសត្រូវ របស់អ្នកដឹកនាំ ក្នុងប្រព័ន្ធគ្រប់គ្រងបរិស្ថាននៃអាជ្ញាធរអប្សរា

**១. អ្នកដឹកនាំថ្នាក់លើ** មានតួនាទី៖

- សំរេចនូវគោលនយោបាយបរិស្ថានជាលាយលក្ខណ៍អក្សរ ថែរក្សា និងផ្សព្វផ្សាយដល់គ្រប់មន្ត្រីនិយោជិតទាំងអស់។
- រៀបចំបំរុង និងផ្តល់នូវប្រភពធនធានចាំបាច់សំរាប់អនុវត្តនិងត្រួតពិនិត្យប្រព័ន្ធគ្រប់គ្រងបរិស្ថាន រួមមាន ធនធានមនុស្ស ជំនាញបច្ចេកទេស និងធនធានផ្នែកហិរញ្ញវត្ថុ។
- ជ្រើសតាំងអ្នកតំណាងគ្រប់គ្រងបរិស្ថាន សំរាប់ទទួលខុសត្រូវជំនួសប្រធានអគ្គនាយក។

**២. អ្នកតំណាងគ្រប់គ្រងបរិស្ថាន** មានតួនាទី៖

- បង្កើត អនុវត្ត និងថែរក្សាប្រព័ន្ធគ្រប់គ្រងបរិស្ថាន ស្របតាមតំរូវការស្តង់ដារអន្តរជាតិ ISO 14001។
- កំណត់នូវទិដ្ឋភាពបរិស្ថានសំខាន់ៗ និងកត់ត្រាទុកជាឯកសារនូវគោលបំណង និងគោលដៅបរិស្ថានរបស់អាជ្ញាធរអប្សរា។
- ពិនិត្យឡើងវិញជាប្រចាំនូវប្រព័ន្ធគ្រប់គ្រងបរិស្ថាន ដើម្បីធានានូវភាពសមស្រប និងប្រសិទ្ធភាពក្នុងការអនុវត្តន៍។

**៣. អ្នកធ្វើសវនកម្មផ្ទៃក្នុង** មានតួនាទី៖

- រៀបចំកម្មវិធីធ្វើសវនកម្ម និងប្រតិបត្តិសវនកម្មផ្ទៃក្នុង ហើយគូសបញ្ជាក់នូវរាល់ចំណុចដែលមិនសមស្រប។
- ធ្វើរបាយការណ៍អំពីលទ្ធផលធ្វើសវនកម្មផ្ទៃក្នុង ទៅប្រធានអគ្គនាយក និងទៅអ្នកតំណាងគ្រប់គ្រងបរិស្ថាន។

**៤. គណៈកម្មការគ្រប់គ្រងបរិស្ថាន** (ដែលមានប្រធាននាយកដ្ឋានទាំង៦ជាសមាជិក) មានតួនាទី៖

- ពិគ្រោះនិងពិភាក្សាអំពីគោលបំណង និងគោលដៅបរិស្ថានរបស់អាជ្ញាធរអប្សរាព្រមជាមួយការដឹកនាំប្រព័ន្ធគ្រប់គ្រងបរិស្ថាន។ល។

• **ប្រធាននាយកដ្ឋាននីមួយៗ** មានតួនាទី៖

- សំរេចនូវគោលបំណង និងគោលដៅបរិស្ថានសំរាប់នាយកដ្ឋានខ្លួនស្របតាមគោលនយោបាយបរិស្ថានរបស់អាជ្ញាធរអប្សរា។
- ទទួលខុសត្រូវចំពោះការអប់រំបរិស្ថានក្នុងនាយកដ្ឋានខ្លួន រួមមានការបណ្តុះបណ្តាល ការយល់ដឹង និងសមត្ថកិច្ចជាដើម។
- ជ្រើសតាំងអ្នកជំរុញការងារបរិស្ថានប្រចាំនាយកដ្ឋានខ្លួន។

**៥. លេខាធិការដ្ឋាន** មានតួនាទី៖

- ជាស្នូលកណ្តាលក្នុងការរៀបចំកិច្ចការចាំបាច់ទាំងឡាយសំរាប់ប្រព័ន្ធគ្រប់គ្រងបរិស្ថានរបស់អាជ្ញាធរអប្សរា។
- រៀបចំសំណុំឯកសារ(Manual)គ្រប់គ្រងបរិស្ថាន និងវិធានការព្រមជាមួយកម្មវិធីគ្រប់គ្រងបរិស្ថានសំរាប់អាជ្ញាធរអប្សរា។
- ប្រតិបត្តិនូវកិច្ចការទាំងឡាយ ក្នុងគោលបំណង បង្កើត អនុវត្ត និងពង្រឹងប្រព័ន្ធគ្រប់គ្រងបរិស្ថាន ក្រោមការណែនាំរបស់អ្នកតំណាងគ្រប់គ្រងបរិស្ថាន។

**៦. ក្រុមជំរុញការងារបរិស្ថាន** មានតួនាទី៖

- ពិគ្រោះ និងពិភាក្សាអំពីការងារដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន វិធីសាស្ត្រអនុវត្តចាំបាច់នានា ដើម្បីសំរេចគោលបំណងនិងគោលដៅបរិស្ថានរបស់នាយកដ្ឋាននីមួយៗ។

• **អ្នកជំរុញការងារបរិស្ថានប្រចាំនាយកដ្ឋាននីមួយៗ** មានតួនាទី៖

- កំណត់នូវទិដ្ឋភាពបរិស្ថានសំខាន់ៗ បង្កើតកម្មវិធីគ្រប់គ្រងបរិស្ថានសំរាប់អនុវត្តនៅក្នុងនាយកដ្ឋានខ្លួន។
- រៀបចំបែបបទគ្រប់គ្រងបរិស្ថាន និងធ្វើរបាយការណ៍ទៅប្រធាននាយកដ្ឋានខ្លួននិងទៅអ្នកតំណាងគ្រប់គ្រងបរិស្ថានអំពីលទ្ធផលនៃការអនុវត្តន៍កម្មវិធីគ្រប់គ្រងបរិស្ថានប្រចាំនាយកដ្ឋានខ្លួន។

## ប្រវត្តិស្តង់ដារអន្តរជាតិ ISO 14001 ស្តីពី "ប្រព័ន្ធគ្រប់គ្រងបរិស្ថាន"

ការប្រើប្រាស់ថាមពលរ៉ែ (ប្រេងឥន្ទនៈ ធ្យូងថ្ម ឧស្ម័ន) បាននាំមកនូវការកើនឡើងនៃកំដៅ និងភ្លៀងអាស៊ីតនៅលើផែនដី ព្រមជាមួយការវិនាសស្រទាប់អូស្សូន។ការកាប់ព្រៃឈើបានបន្ថយនូវបរិមាណទឹកភ្លៀងប្រចាំឆ្នាំនិងបង្កើតបាតុភូតផ្សេងៗ ដែលនាំមកនូវបន្ទុកដ៏ធ្ងន់ធ្ងរចំពោះផែនដីទាំងមូល។

ដើម្បីដោះស្រាយបញ្ហាដែលមានលក្ខណៈជាសកល សន្ធិសញ្ញាអន្តរជាតិផ្សេងៗកំពុងតែត្រូវបានរៀបចំឡើង ក៏ប៉ុន្តែ "ផែនដីដែលកខ្វក់ម្តងហើយ" មិនអាចត្រឡប់មកជា "ផែនដីស្អាត" ដូចដើមវិញបានឡើយ។

នៅក្នុងដំណើរហេតុដូចនេះហើយ ទើបអង្គការអន្តរជាតិសំរាប់ស្តង់ដារូបនីយកម្ម (ហៅISO) បានពិភាក្សាជំរុញបង្កើតស្តង់ដារមួយ ដើម្បីឲ្យសហគ្រាសឬក្រុមហ៊ុននីមួយៗ អាចចូលរួមចំណែកកែលំអជានិរន្តនូវបញ្ហាបរិស្ថាននេះ ពោលគឺ ការបង្កើតស្តង់ដារអន្តរជាតិ ***ISO 14001*** ស្តីពី *"ប្រព័ន្ធគ្រប់គ្រងបរិស្ថាន"* ដែលបានសំរេចជាផ្លូវការនៅខែមិថុនាឆ្នាំ១៩៩៦។

ឆ្នាំ១៩៩១ សន្និសីទអ្នកជំនាញសេដ្ឋកិច្ច (BCSD) ស្តីពី "អភិវឌ្ឍន៍ដែលអាចប្រព្រឹត្តជានិរន្តរ៍" ប្រកាសសេចក្តីសំរេចចិត្តបង្កើតស្តង់ដារអន្តរជាតិមួយ ដោយផ្ញើអន្តរាគមទៅអង្គការ ISO ។

ឆ្នាំ១៩៩២ សេចក្តីសំរេចយកប្រកាសក្រុង Rio(Rio Declaration on Environment and Development and the Provision of Agenda 21)នៃសន្និសីទកំពូលស្តីពីផែនដី(សន្និសីទអង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍បរិស្ថាន)

ឆ្នាំ១៩៩៣ បង្កើតគណៈកម្មការបច្ចេកទេស TC 207 នៅក្នុងអង្គការ ISO ដើម្បីទទួលបន្ទុកកិច្ចការទាំងនេះ។

ឆ្នាំ១៩៩៥ យល់ព្រមនិងប្រកាសពង្រាងស្តង់ដារអន្តរជាតិ (DIS)

ឆ្នាំ១៩៩៦ អនុម័តស្តង់ដារអន្តរជាតិ ISO 14001

### កម្មវិធីអនុវត្តគំរោង

| ឆ្នាំ ខែ / សកម្មភាព | ឆ្នាំទី ១ | | | | | | | | | | | | ឆ្នាំទី ២ | | | | | | | | | | | | ឆ្នាំទី ៣ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ |
| វាស់វែងបរិស្ថាន | | | | | | | | | ■ | | | | | | ■ | | | | | | ■ | | | | | | ■ | | | | | | ■ | | | |
| អប់រំបុគ្គលិក និងផ្តល់ការយល់ដឹង | | ■ | ■ | ■ | ■ | ■ | ■ | | | | | | | ■ | ■ | | | | | | | | | | | | | | | | | | | | | |
| សិក្សានិងអនុវត្តគំរោងគំរូ (ការគ្រប់គ្រងសំរាម) | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| រៀបចំបង្កើត ប្រព័ន្ធគ្រប់គ្រងបរិស្ថាន | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | |
| ប្រតិបត្តិ ប្រព័ន្ធគ្រប់គ្រងបរិស្ថាន | | | | | | | | | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |

(EMS: Environmental Management System, ប.គ.ប.: ប្រព័ន្ធគ្រប់គ្រងបរិស្ថាន)

គំរោងគ្រប់គ្រងបរិស្ថានអង្គរក្រោមសហការរវាងអាជ្ញាធរអប្សរានិងភាគីចំរុះជប៉ុន បានចាប់បដិសន្ធិនៅ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៣។ ដើម្បីសំរួលឲ្យគំរោងនេះអនុវត្តទៅ ដោយប្រសិទ្ធិភាពខ្ពស់ ឯកឧត្តម ប៊ុន ណារិទ្ធ ប្រធានអគ្គនាយកបានចេញសេចក្តីសំរេចលេខ២១៨រក.សសរ ចុះថ្ងៃទី១៨ខែមេសា ឆ្នាំ២០០៣ ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងបរិស្ថានមួយ ដើម្បីគ្រប់គ្រងបរិស្ថាននៅអង្គរ ស្របតាមស្តង់ដារអន្តរជាតិ ISO 14001 ដែលមានឈ្មោះថា *អង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថាន* និង មានការិយាល័យនៅ *មណ្ឌលអន្តរជាតិតម្កល់ឯកសារអង្គរ* ។



## សកម្មភាពការងារក្នុងអង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថាន

មកទល់ពេលនេះ អង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថាន បានដំណើរការជាជំហានៗតាមកម្មវិធីអនុវត្តគំរោងរបស់ខ្លួន ដែលមានជាគោល។ ដូចខាងក្រោមនេះ ៖

### ១. សកម្មភាពនៃគណៈកម្មការគ្រប់គ្រងបរិស្ថាន

ការពិគ្រោះពិភាក្សា រវាងថ្នាក់ដឹកនាំនៃអាជ្ញាធរអប្សរា ស្តីពីការបង្កើតរចនាសម្ព័ន្ធ ព្រមជាមួយកិច្ចការចាំបាច់សំរាប់គ្រប់គ្រងបរិស្ថានអង្គរ បានប្រព្រឹត្តឡើងនៅលើកទី១ថ្ងៃទី២៩ខែឧសភា ឆ្នាំ២០០៣ និងលើកទី២ថ្ងៃទី១៥ខែកញ្ញាឆ្នាំ២០០៣។



*ការប្រជុំពិភាក្សា រវាងថ្នាក់ដឹកនាំនៃអាជ្ញាធរអប្សរា (១៥កញ្ញា២០០៣)*

### ២. ការសិក្សាអំពីស្ថានភាពសំរាមនាពេលបច្ចុប្បន្ន

តាមរយៈការចុះទៅអង្កេតផ្ទាល់នូវស្ថានភាពសំរាម តាមដងស្ទឹងសៀមរាប និងក្នុងឧទ្យានអង្គរ នាពេលនោះ យើងសង្កេតឃើញមានសំរាមជាច្រើនកន្លែងដែលនៅពុំទាន់មានវិធានការចាត់ចែងនៅឡើយ។



*សំរាមនៅតាមដងស្ទឹងសៀមរាប (៤មិថុនា២០០៣)*



*សំរាមនៅតាមព្រៃក្បែរប្រាសាទ (២០កក្កដា២០០៣)*

## ៣. ការសិក្សាប្រព័ន្ធគ្រប់គ្រងបរិស្ថាននៅក្នុងអាជ្ញាធរអប្សរា

ការបង្ហាត់បង្រៀនក្រុមលេខាធិការ និងក្រុមជំរុញការងារបរិស្ថានប្រចាំនាយកដ្ឋាននីមួយៗអំពីស្តង់ដារអន្តរជាតិ ISO 14001 និងគំរូវការនានាក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងបរិស្ថាននៅអង្គរ។

- ៩កញ្ញា២០០៣ សិក្សាទំរង់ទូទៅនៃប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងមាត្រាខ្លះនៃស្តង់ដារ ISO 14001 ។
- ១៥កញ្ញា២០០៣ សិក្សាបញ្ហាគ្រប់គ្រងសំរាមទាក់ទងនឹងសកម្មភាពរបស់អាជ្ញាធរអប្សរា។
- ១៩កញ្ញា២០០៣ពិភាក្សាសកម្មភាពប្រចាំនាយកដ្ឋាននីមួយៗ និងវិភាគទិន្នន័យសំរាមដែលបានអង្កេត និងបកស្រាយស្តង់ដារ។
- ៣តុលា២០០៣ ពិភាក្សាគោលបំណងនិងគោលដៅបរិស្ថានប្រចាំនាយកដ្ឋាននីមួយៗ និងបកស្រាយស្តង់ដារ។
- ១០តុលា២០០៣ពិភាក្សានិងសិក្សាឯកសារចាំបាច់សំរាប់ ប.គ.ប.។



*ការប្រជុំអ្នកជំរុញការងារបរិស្ថានប្រចាំនាយកដ្ឋាននីមួយៗរៀងរាល់ព្រឹកថ្ងៃសុក្រ*

## ៤. ការផ្សព្វផ្សាយទៅស្ថាប័នខាងក្រៅ

- ការចុះទៅទំនាក់ទំនងការងារជាមួយសាលាបឋមសិក្សាក្រវ៉ាន់ និងស្រះស្រង់ខាងជើង និងស្ថាប័នខេត្តដូចជាមន្ទីរបរិស្ថាន និងមន្ទីរកសិកម្ម និងជាមួយអង្គការក្រៅរដ្ឋាភិបាល ដូចជាអង្គការងឹនការរ៉េត អង្គការ APDO និងអង្គការស្នាដៃខ្មែរ។
- ការបង្ហាញគំរោងប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ នៅក្នុងសម័យប្រជុំពេញអង្គលើកទី១០ នៃគណៈកម្មការអន្តរជាតិសម្របសម្រួលការការពារនិងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្រ្តអង្គរ (ICC)។




*ការពន្យល់បង្ហាញអំពីគំរោង ចំពោះអង្គប្រជុំ ICC (២៧មិថុនា២០០៣)*

- ការរៀបចំសំនួរដើម្បីសម្ភាស អ្នកលក់ដូរនៅក្នុងឧទ្យានអង្គរ ស្តីពីប្រភព ប្រភេទ និងបរិមាណនៃសំរាម ក្នុងគោលបំណងបង្កើតគោលដៅ និងកម្មវិធីគ្រប់គ្រងសំរាមនៅឧទ្យានអង្គរ។



*សកម្មភាពសម្ភាសអ្នកលក់នៅអង្គរវត្ត និងបរិវេណអង្គរធំ (២២សីហា២០០៣)*

### *ពន្យល់ពាក្យ*

***ISO** (International Organization for Standardization):* *អង្គការអន្តរជាតិសំរាប់ស្តង់ដារូបនីយកម្ម* (មានទីស្នាក់ការនៅស៊ុីស)

***EMS** (Environmental Management System):* *ប្រព័ន្ធគ្រប់គ្រងបរិស្ថាន (ប.គ.ប.)*

***បរិស្ថាន** (Environment):* អ្វីៗដែលអោបក្រសោបសកម្មភាពរបស់អាជ្ញាធរ ដែលក្នុងនោះរួមមាន អាកាស ទឹក ដី ធនធានធម្មជាតិ រុក្ខជាតិ សត្វ មនុស្សព្រមជាមួយទំនាក់ទំនងគ្នាទៅវិញទៅមកនៃអ្វីៗទាំងនេះ(“អ្វីៗដែលអោបក្រសោប” នៅទីនេះ លាតសន្ធឹងចាប់តាំងពីក្នុងអង្គភាពមួយរហូតទៅដល់ប្រព័ន្ធផែនដីទាំងមូល) ។

***ទិដ្ឋភាពបរិស្ថាន** (Environmental Aspect):* ធាតុនៃសកម្មភាព ផលិតផល ឬសេវាកម្ម របស់អាជ្ញាធរដែលអាចជះឥទ្ធិពលទៅវិញទៅមក (អន្តរកម្ម) ជាមួយបរិស្ថាន (*ទិដ្ឋភាពបរិស្ថានសំខាន់* គឺជា ទិដ្ឋភាពបរិស្ថានដែលមានឬអាចនឹងមានឥទ្ធិពលខ្លាំងទៅលើបរិស្ថាន) ។

***គោលនយោបាយបរិស្ថាន** (Environmental Policy):* សេចក្តីប្រកាសធ្វើឡើងដោយអាជ្ញាធរ អំពី ចន្ទៈនិងគោលការណ៍របស់ខ្លួន ពាក់ព័ន្ធទៅនឹងលទ្ធផលនៃការអនុវត្តន៏បរិស្ថានទាំងមូលរបស់ខ្លួន ដែលផ្តល់ទំរង់លក្ខណៈមួយសំរាប់ធ្វើសកម្មភាព ព្រមទាំងសំរាប់កំណត់គោលបំណងនិងគោលដៅបរិស្ថានទាំងឡាយរបស់ខ្លួន។

***គោលបំណងបរិស្ថាន** (Environmental Objective):* ចំណុចទៅដល់ចុងក្រោយនៃបរិស្ថានទាំងមូល ដែលកើតចេញមកពីគោលនយោបាយបរិស្ថាន ដែលអាជ្ញាធរបានកំណត់ដោយខ្លួនឯងដើម្បីសំរេចឲ្យបាន ហើយដែលត្រូវដាក់ជាបរិមាណក្នុងករណីអាចធ្វើបាន។

***គោលដៅបរិស្ថាន** (Environmental Target):* ការទាមទារលទ្ធផលលំអិតនៃការអនុវត្តន៏ ដោយដាក់ជាបរិមាណក្នុងករណីអាចធ្វើបាន សំរាប់អាជ្ញាធរឬផ្នែកទាំងឡាយនៃអាជ្ញាធរ ដែលកើតចេញមកពីគោលបំណងបរិស្ថាន ហើយដែលត្រូវការកំណត់ និងឆ្លើយតប ដើម្បីសំរេចឲ្យបាននូវគោលបំណងទាំងនោះ។

### ការប្តេជ្ញាចិត្តរបស់លេខាធិការដ្ឋាន

យើងខ្ញុំព្យាយាមរៀនសូត្រនូវប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ ឱ្យបានយល់ច្បាស់ប្រយោជន៍ធ្វើការផ្សព្វផ្សាយ ដល់ស្ថាប័នពាក់ព័ន្ធ អ្នកស្រុក ព្រមទាំងភ្ញៀវទេសចរ ចូលរួមសហការ និងអនុវត្តប្រព័ន្ធខាងលើទាំងអស់គ្នា ដើម្បីឲ្យអង្គររក្សាបានសំរស់ស្រស់បំព្រងតរៀងទៅ។

ព្រឹត្តិប័ត្រពត៌មាន : *បរិស្ថានអង្គរ*
ឆ្នាំទី១ លេខដំបូង ថ្ងៃពុធ ទី១៥ ខែតុលា ឆ្នាំ២០០៣
ផ្សាយចេញពី : អង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថាន អាជ្ញាធរអប្សរា
អាស័យដ្ឋាន : មណ្ឌលអន្តរជាតិតម្កល់ឯកសារអង្គរ
ក្រុម៣ ភូមិទ្រាំង ឃុំស្លក្រាម សៀមរាប
ទូរស័ព្ទ / ទូរសារ : ០៦៣-៩៦៤-៨៣៦